**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

សេចក្តីប្រកាសព័ត៌មាន

# សម្តេចធិបតី ហ៊ុន ម៉ាណែត ជួបពិភាក្សាការងារជាមួយ ថ្នាក់ដឹកនាំប្រទេសវៀតណាម មីយ៉ាន់ម៉ា និងអភិបាលខេត្តយូណាន ព្រមទាំងជួបជាមួយធុរជនចិន និងនិស្សិតកម្ពុជា នៅខេត្តយូណាន

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានជួបពិភាក្សាការងារជាមួយ **ឯកឧត្តម** Wang Yubo អភិបាលខេត្តយូណាននៃសាធារណរដ្ឋប្រជាមានិតចិនឯក **ឯកឧត្តម** Pham Minh Chinh នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋសង្គមនិយមវៀតណាម **ឯកឧត្តមនាយឧត្តមសេនីយ៍ជាន់ខ្ពស់** Min Aung Hlaing ប្រធានក្រុមប្រឹក្សារដ្ឋបាលរដ្ឋនៃសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា ក៏ដូចជាតំណាងក្រុមហ៊ុនចិន ក្នុងឱកាសនៃការចូលរួមកិច្ចប្រជុំកំពូលចំនួន ៣ ក្រោមក្របខ័ណ្ឌមេគង្គ រួមមានកិច្ចប្រជុំកំពូលមហាអនុតំបន់មេគង្គលើកទី៨ កិច្ចប្រជុំកំពូលអេកម៉ិកលើកទី១០ និងកិច្ចប្រជុំកំពូល CLMV លើកទី១១ ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី៥-៧ ខែវិច្ឆិកា ឆ្នាំ២០២៤ ទីក្រុងគុនមិញ ខេត្តយូណាន ប្រទេសចិន។

នៅថ្ងៃទី៥ ខែវិច្ឆិកា **សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានទទួលជំនួបសម្តែងការគួរសមពី **ឯកឧត្តម** Wang Yubo អភិបាលខេត្តយូណាន ដែលបានទទួលស្វាគមន៍ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** យ៉ាងកក់ក្តៅមកកាន់ខេត្តយូណាន។ ភាគីទាំងពីរបានរំលឹកឡើងវិញនូវការប្រាស្រ័យទាក់ទងជាញឹកញាប់រវាងថ្នាក់ដឹកនាំកម្ពុជា និងចិន ដែលពង្រឹងទំនាក់ទំនងយ៉ាងជិតស្និទ្ធ និងកិច្ចសហប្រតិបត្តិការប្រកបដោយផ្លែផ្កាវវាងប្រទេសទាំងពីរ។ ភាគីទាំងពីរបានកត់សម្គាល់ដោយការពេញចិត្តយ៉ាងខ្លាំងចំពោះការរួមចំណែកយ៉ាងសំខាន់របស់ខេត្តយូណាន ដល់ក្នុងការរីកចម្រើនផ្នែកពាណិជ្ជកម្ម និងវិនិយោគរវាងកម្ពុជា និងចិន។ ភាគីទាំងពីរបានអបអរសាទរចំពោះការបើកដំណើរការអាកាសយានដ្ឋានអន្តរជាតិសៀមរាបអង្គរ កាលពីឆ្នាំមុន ដែលត្រូវបានសាងសង់ឡើងក្រោមការវិនិយោគពីខេត្តយូណាន។ ភាគីទាំងពីរបានឯកភាពពីសារសំខាន់នៃកិច្ចខិតខំប្រឹងប្រែងរួមគ្នាដើម្បីធានាថាអាកាសយានដ្ឋានថ្មីនឹងបម្រើដល់វិស័យទេសចរណ៍ និងលើកកម្ពស់កំណើនសេដ្ឋកិច្ច។ **សម្តេចធិបតីនាយករដ្ឋមន្ត្រី**

អាសយដ្ឋាន: លេខ ៣ វិថី **សម្តេច ហ៊ុន សែន**
សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (855) 23 216 1[illegible]
ទូរសារ : (855) 23 216 141, 023 213 [illegible]
អ៊ីម៉ែល : mfaic@mfaic.gov.kh

បានថ្លែងអំណរគុណដល់អភិបាលខេត្តយូណាន សម្រាប់ការផ្តល់អាហារូបករណ៍ និងវគ្គបណ្តុះបណ្តាល ដល់និស្សិតកម្ពុជា និងស្វាគមន៍ចំពោះការប្តេជ្ញាចិត្តរបស់ **ឯកឧត្តម** Wang Yubo ក្នុងការជំរុញឱ្យមានការវិនិយោគ និងភ្ញៀវទេសចរកាន់តែច្រើនពីខេត្តយូណានមកកម្ពុជា។

**សម្តេចធិបតីនាយករដ្ឋមន្ត្រី** ក៏មានជំនួបដាច់ដោយឡែកជាមួយ **ឯកឧត្តមនាយឧត្តមសេនីយ៍ជាន់ខ្ពស់** Min Aung Hlaing ប្រធានក្រុមប្រឹក្សារដ្ឋបាលរដ្ឋ នៃសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា និង **ឯកឧត្តម** Pham Minh Chinh នាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋសង្គមនិយមវៀតណាម។ ជំនួបជាមួយ **ឯកឧត្តម** Min Aung Hlaing បានផ្តោតលើការជំរុញកិច្ចសហប្រតិបត្តិការទ្វេភាគីលើវិស័យពាណិជ្ជកម្ម ការវិនិយោគ ការផ្លាស់ប្តូររវាងប្រជាជននិងប្រជាជន និងទេសចរណ៍ តាមរយៈសកម្មភាពរួមគ្នាជាពិសេសក្នុងឱកាសខួបគម្រប់លើកទី៧០នៃទំនាក់ទំនងការទូតកម្ពុជា-មីយ៉ាន់ម៉ានៅឆ្នាំក្រោយ។ ភាគីទាំងពីរក៏បានផ្លាស់ប្តូរយោបល់អំពីកិច្ចខិតខំប្រឹងប្រែងដើម្បីដោះស្រាយវិបត្តិនយោបាយនៅក្នុងប្រទេសមីយ៉ាន់ម៉ា និងបទពិសោធន៍របស់កម្ពុជាក្នុងការកសាងសន្តិភាព និងការផ្សះផ្សាជាតិ។ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានលើកឡើងពីតួនាទីដ៏សំខាន់របស់អាស៊ានក្នុងការជួយដល់មីយ៉ាន់ម៉ាឱ្យវិលទៅរកភាពប្រក្រតីវិញ ហើយបានបញ្ជាក់ជាថ្មីពីការប្តេជ្ញាចិត្តរបស់កម្ពុជាក្នុងការជួយដល់ដំណោះស្រាយសន្តិភាពប្រកបដោយបរិយាបន្នដែលដឹកនាំ និងគ្រប់គ្រងដោយមីយ៉ាន់ម៉ាផ្ទាល់។

**សម្តេចធិបតីនាយករដ្ឋមន្ត្រី** និង **ឯកឧត្តម** Pham Minh Chinh បានអបអរសាទរគ្នាទៅវិញទៅមកចំពោះការសម្រេចបានសមិទ្ធផលសេដ្ឋកិច្ច និងសង្គមរបស់ប្រទេសទាំងពីរ ព្រមទាំងបានសម្តែងនូវការពេញចិត្តចំពោះទំនាក់ទំនងកាន់តែជិតស្និទ្ធនិងការរីកចម្រើននៃកិច្ចសហប្រតិបត្តិការនៅក្នុងវិស័យជាច្រើនរវាងកម្ពុជា និងវៀតណាម។ **នាយករដ្ឋមន្ត្រីទាំងពីរ** បានឯកភាពបង្កើនកិច្ចខិតខំប្រឹងប្រែងក្នុងការជំរុញការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធ ដើម្បីសម្រួលដល់ការធ្វើដំណើរប្រជាជន និងការដឹកជញ្ជូនទំនិញ។ ទំហំពាណិជ្ជកម្មមានការកើនឡើងប្រមាណ ២២% ក្នុងរយៈពេល១០ខែនៃឆ្នាំ២០២៤ ហេតុនេះថ្នាក់ដឹកនាំទាំងពីរបានប្តេជ្ញាចិត្តជំរុញស្ថាប័នពាក់ព័ន្ធឱ្យខិតខំធ្វើការឆ្ពោះទៅការសម្រេចគោលដៅនៃទំហំពាណិជ្ជកម្ម ១០ប៊ីលានដុល្លាអាមេរិក និងលើកទឹកចិត្តបន្ថែមទៀតដល់ការវិនិយោគទ្វេភាគី។ ទន្ទឹមនឹងនេះ ការបង្កើនការផ្លាស់ប្តូរវប្បធម៌ និងយុវជនត្រូវបានចាត់ទុកជាការរួមចំណែកដល់ការជំរុញទំនាក់ទំនងរវាងប្រជាជន និងប្រជាជនផងដែរ។ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** និង **ឯកឧត្តម** Pham Minh Chinh ទន្ទឹងរង់ចាំធ្វើការប្រាស្រ័យទាក់ទងនៅក្នុងកិច្ចប្រជុំកម្រិតខ្ពស់រវាងប្រទេសទាំងពីរ នាពេលខាងមុខ និងបានអះអាងសាជាថ្មីនូវការប្តេជ្ញាចិត្តពន្លឿនការបញ្ចប់កិច្ចការបោះបង្គោលព្រំដែនដែលនៅសេសសល់។ ឆ្លៀតក្នុងឱកាសនោះ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណដល់វៀតណាមសម្រាប់ការជួយសម្របសម្រួលដល់ពិធីដង្ហែអង្គកឋិនទានឆ្ពោះទៅកាន់វត្តពោធិគិរីវង្សារាម នៅខេត្តត្រាវិញ ព្រមទាំងការទទួលស្វាគមន៍ដ៏កក់ក្តៅជូនចំពោះ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា និងគណៈប្រតិភូ។

ខណៈពេលស្នាក់នៅទីក្រុងគុនមិញ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានទទួលជួបសម្តែងការគួរសមដាច់ដោយឡែកពីសំណាក់តំណាងក្រុមហ៊ុនចិនចំនួន៧ ដែលបានបង្ហាញអំពីគម្រោងពាណិជ្ជកម្ម និងការវិនិយោគសម្រាប់កម្ពុជា រួមមានក្រុមហ៊ុន Zhengzhou Chen´s Sun ក្រុមហ៊ុន ZhongJiao Tongli ក្រុមហ៊ុន Guoxing Group ក្រុមហ៊ុន Shandong (Cambodia) Economic and Technological Development Zone ក្រុមហ៊ុន Ju Wang Footwear Co., Ltd និង Juhuiland Co Ltd., ក្រុមហ៊ុន Yunnan Investment Group និង ក្រុមហ៊ុន Sailun Group។ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** ក៏បានជួបសំណេះសំណាលជាមួយនិស្សិតកម្ពុជាដែលកំពុងសិក្សានៅខេត្តយូណាន ព្រមទាំងបានជំរុញឱ្យប្អូនៗនិស្សិតខិតខំរៀនសូត្រ ដើម្បីក្លាយជាសមាជិកល្អរបស់គ្រួសារ និងសហគមន៍របស់ខ្លួន៕

ថ្ងៃព្រហស្បតិ៍ ៧ កើត ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០២៤